ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...៨៤៧១.......អពដ

L202105030016 | TD2805

ថ្ងៃព្រហស្បតិ៍ ៧កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## គោលការណ៍ណែនាំទាក់ទិននឹងការដាក់បញ្ចូលទម្រង់លេខអត្តសញ្ញាណកម្មសារពើពន្ធអ្នកជាប់ពន្ធជនជាតិអាមេរិក (U.S. TIN)

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ធនាគារសហគ្រាសធានារ៉ាប់រង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនមូលបត្រ និងស្ថាប័នប្រហាក់ប្រហែលដទៃទៀត ដែលជាគ្រឹះស្ថាន-ហិរញ្ញវត្ថុ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសស្តីពីការអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលសហរដ្ឋអាមេរិកដើម្បីធ្វើឱ្យប្រសើរឡើងនូវអនុលោមភាពពន្ធអន្តរជាតិ និងអនុវត្តច្បាប់ស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក (FATCA) ឱ្យបានជ្រាបថា ក្នុងគោលបំណងស្វែងយល់អំពីផលវិបាកក្នុងការទទួលបាននិងស្វែងរកព័ត៌មាន U.S. TIN ឱ្យមានប្រសិទ្ធភាពខ្ពស់ អាជ្ញាធរចំណូលផ្ទៃក្នុងសហរដ្ឋអាមេរិក (IRS) ស្នើសុំឱ្យគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ដែលពុំមានព័ត៌មាន U.S. TIN របស់អតិថិជន ត្រូវបញ្ចូលទម្រង់លេខចំនួន ០៩ ខ្ទង់ នៅក្នុងប្រអប់ TIN សម្រាប់ការរាយការណ៍ព័ត៌មានគណនីជនជាតិអាមេរិកដែលត្រូវរាយការណ៍ចាប់ពីឆ្នាំប្រតិទិន២០២០តទៅ តាមករណីនីមួយៗ ដូចខាងក្រោម÷

១. បញ្ចូលទម្រង់ 222222222 ក្នុងករណីគណនីមានស្រាប់និងកាន់កាប់ដោយរូបវន្តបុគ្គល (Preexisting Individual Account) ជនជាតិអាមេរិកដែលមានទីកន្លែងកំណើតនៅសហរដ្ឋអាមេរិក។

២. បញ្ចូលទម្រង់ 333333333 ក្នុងករណីគណនីបង្កើតថ្មីនិងកាន់កាប់ដោយរូបវន្តបុគ្គល (New Individual Account) ជនជាតិអាមេរិកមានទីកន្លែងកំណើតនៅសហរដ្ឋអាមេរិកនិងមានលក្ខខណ្ឌណាមួយដូចខាងក្រោម÷
   - ក. ព័ត៌មានទទួលបានតាម "ការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification)" នៅពេលបើកគណនី ពុំត្រឹមត្រូវឬពុំអាចជឿទុកចិត្តបាន ហើយគ្រឹះស្ថានហិរញ្ញវត្ថុនៅពុំទាន់ទទួលបាន "ការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification)" ថ្មី ឬ
   - ខ. នៅពេលបើកគណនី សមតុល្យគណនីស្ថិតនៅក្រោមកម្រិតដែលត្រូវកត់ត្រានិងរាយការណ៍ ប៉ុន្តែក្រោយមកសមតុល្យគណនីនោះលើសកម្រិតដែលត្រូវកត់ត្រា និងរាយការណ៍ ហើយគ្រឹះស្ថាន-ហិរញ្ញវត្ថុនៅពុំទាន់ទទួលបាន "ការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification)"។

៣. បញ្ចូលទម្រង់ 444444444 ក្នុងករណីគណនីមានស្រាប់និងកាន់កាប់ដោយរូបវន្តបុគ្គល (Preexisting Individual Account) ឬគណនីមានស្រាប់និងកាន់កាប់ដោយនីតិបុគ្គល (Preexisting Entity Account) ជាជនជាតិអាមេរិកដែលមានទីកន្លែងកំណើតក្រៅពីសហរដ្ឋអាមេរិក និងមានលក្ខខណ្ឌណាមួយដូចខាងក្រោម÷
   - ក. ព័ត៌មានទទួលបានតាម "ការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification)" ឬឯកសារផ្សេងទៀតនៅពេលបើកគណនី ពុំត្រឹមត្រូវឬពុំអាចជឿទុកចិត្តបាន ហើយគ្រឹះស្ថានហិរញ្ញវត្ថុនៅពុំទាន់ទទួលបាន "ការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification)" ថ្មី ឬឯកសារថ្មីផ្សេងទៀត ឬ



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

ខ. នៅពេលបើកគណនី សមតុល្យគណនីស្ថិតនៅក្រោមកម្រិតដែលត្រូវកត់ត្រានិងរាយការណ៍ ប៉ុន្តែក្រោយមកសមតុល្យគណនីនោះលើសកម្រិតដែលត្រូវកត់ត្រានិងរាយការណ៍ ហើយគ្រឹះស្ថាន-ហិរញ្ញវត្ថុនៅពុំទាន់ទទួលបាន "ការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification)" ឬឯកសារផ្សេងទៀត។

៤. បញ្ចូលទម្រង់ 555555555 ក្នុងករណីគណនីបង្កើតថ្មីនិងកាន់កាប់ដោយរូបវន្តបុគ្គល (New Individual Account) ឬគណនីបង្កើតថ្មីនិងកាន់កាប់ដោយនីតិបុគ្គល (New Entity Account) ជាជនជាតិអាមេរិកដែលមានទីកន្លែងកំណើតក្រៅពីសហរដ្ឋអាមេរិក និងមានលក្ខខណ្ឌណាមួយដូចខាងក្រោម÷

ក. ព័ត៌មានទទួលបានតាម "ការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification)" ឬឯកសារផ្សេងៗទៀត នៅពេលបើកគណនីពុំត្រឹមត្រូវឬពុំអាចជឿទុកចិត្តបាន ហើយគ្រឹះស្ថានហិរញ្ញវត្ថុនៅពុំទាន់ទទួលបាន "ការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification)" ថ្មី ឬឯកសារថ្មីផ្សេងទៀត ឬ

ខ. នៅពេលបើកគណនី សមតុល្យគណនីស្ថិតនៅក្រោមកម្រិតដែលត្រូវកត់ត្រានិងរាយការណ៍ ប៉ុន្តែក្រោយមកសមតុល្យគណនីនោះលើសកម្រិតដែលត្រូវកត់ត្រា និងរាយការណ៍ ហើយគ្រឹះស្ថាន-ហិរញ្ញវត្ថុនៅពុំទាន់ទទួលបាន "ការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification)" ឬឯកសារផ្សេងទៀត។

៥. បញ្ចូលទម្រង់ 666666666 ក្នុងករណីគណនីមានស្រាប់និងកាន់កាប់ដោយនីតិបុគ្គល (Preexisting Entity Account) ដែលមានសមតុល្យគណនីលើសពី ១ ០០០ ០០០ (មួយលាន) ដុល្លារអាមេរិក ដែលបានចាត់ទុកថាជា "Passive NFFE" ដោយសារនីតិបុគ្គលនេះពុំបានធ្វើការប្រកាសបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួន (self-certification) ហើយគ្រឹះស្ថានហិរញ្ញវត្ថុពុំអាចកំណត់បាននូវអត្តសញ្ញាណជនជាតិអាមេរិករបស់ម្ចាស់គណនី។

៦. បញ្ចូលទម្រង់ 777777777 ក្នុងករណីគណនីមានស្រាប់ (Preexisting Account) ជាគណនីអសកម្ម (Dormant or Inactive Account) ដែលមានសមតុល្យគណនីលើសកម្រិតដែលត្រូវកត់ត្រានិងរាយការណ៍។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា ធនាគារ សហគ្រាសជានាវ៉ាប់រង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនមូលបត្រ និងស្ថាប័នប្រហាក់ប្រហែលដទៃទៀត ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុនឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងករណីមានបញ្ហា ឬចម្ងល់ផ្សេងៗ សូមទំនាក់ទំនងមកអាសយដ្ឋានសារអេឡិចត្រូនិក fatca@tax.gov.kh ឬទូរស័ព្ទលេខ ០២៣ ៨៨៣ ៧២៧។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**